យល់តែធ្វើជាចចេស គន្ធាប្រកែកញ៉ាញ៖

«ខ្ញុំមិនយល់ទេ ពាក្យទំនាយស្អី?»

យាយបិទភ្នែកស្ងឹងស្មាធិ៍។ សម្រាប់ធីតានិងដាណែវិញ ពេលនេះស្តាប់អ្វីដែលយាយនិយាយខ្លីៗក៏យល់ថា គាត់ពិតជាអ្នកចេះផ្លូវងងឹតមែនបានជាដឹងអាថ៌កំបាំងរបស់ពួកគេ។

«លោកយាយ មេត្តាជួយ....ជួយ....ខ្ញុំ....ផង! ខ្ញុំភ័យណាស់!»

«ណែះឯង!!!! កុំស្លន់ស្លោពេកនាង!»

គន្ធាចង្អុលមុខដាក់ដាណែនិងធីតាដែលពិតជាបាក់បបខ្លបខ្លាចសឹងនិយាយសារភាពគ្រប់យ៉ាង។

«ច្រើនឆ្នាំមកនេះខ្ញុំដឹងខុសហើយ ខ្ញុំខំធ្វើបុណ្យណាស់!» ធីតានិយាយឡើងមិនខ្វល់នឹងគន្ធា ធ្វើឱ្យគន្ធាកេះផងក្តិចផង៖

«បិទមាត់អីខ្លះទៅ!»

យាយញញឹមបើកភ្នែក ហើយនិយាយមួយៗ៖

«ដែលពួកចៅបិទមាត់....បាន! ប៉ុន្តែចិត្តចៅនៅរស់រវើក នៅនឹកឃើញ! ឥឡូវនេះ...ដល់ពេលវេលាដែលម្ចាស់បំណុលកម្មគេមកទារសំណងហើយ ហុកសិបខែ! ជាពេលដែលអំណាចម្ចាស់បំណុលកាន់តែធំធេងឡើង! ទោះយប់ឬថ្ងៃ រឿងនោះនឹងអន្ទោលតាមចៅ!»

ពួកគេរាប់ដៃ។

ជាងហុកសិបខែ បានន័យប្រាំឆ្នាំ។

ចាប់ពីថ្ងៃដែលគេធ្វើឱ្យស្រីមុំដួលពិការនិងថ្ងៃដែលយាយពិការបានស្លាប់ក្នុងទឹក។

«ដោះស្រាយយ៉ាងម៉េចទៅ?»

ដាណែស្ទួររញីរញ័រដោះកងពីដៃហុចទៅឱ្យគាត់។ វាជាកងដៃពេជ្រសែនមានតម្លៃ ប៉ុន្តែគាត់មិនទទួលទេ។

«យាយបានត្រឹមជួយរំឭកប្រាប់ ប៉ុន្តែទោសនេះ យាយមិនមានសមត្ថភាពអាចជួយបានទេ! លោកនេះគ្មានអ្នកណាអាចដោះពាក្យទំនាយមុនស្លាប់បានទេ! វាជាភាសាផ្ញើនឹងទ្វីបលោក ដោះមិនរួចទេចៅអើយ»

«ធ្វើម៉េចទៅ? និយាយនេះចង់ឱ្យខ្ញុំសម្លាប់ខ្លួនទៅតាមកំហុសហ្មែន?»

«ចៅៗ ទៅទទួលទោស!»

«និយាយអ៊ីចឹងឱ្យខ្ញុំទៅចូលគុកមិនមែន? វាដួលនោះ ជាព្រហ្មលិខិត! អ្នកណាដែលដឹងថា មានដែកនៅហ្នឹង? តោះទៅវិញ!»

គន្ធាខឹងនិងហៅពួកម៉ាក តែពួកម៉ាកសុទ្ធតែញាក់។

ត្រចៀកពួកគេឮតែសំឡេងដាក់ទំនាយចាស់។

«នៅអង្គុយស្ដាប់សិន!» យាយអាវសពោលឃាត់។

ដោយឃើញគ្មានអ្នកណាព្រមក្រោកមកតាម គន្ធាក៏ព្រមនៅបន្តទាំងខឹងទាំងជា តែតាំងចិត្តថាមិនស្ដាប់។

«លោកយាយ» ធីតាយំ «ពួកខ្ញុំធ្លាប់មានកំហុសមែន ប៉ុន្តែកាលណោះនៅក្មេងពេកមិនយល់អ្វី!»

«ពួកឯងទៅទទួលទោស បើមិនអ៊ីចឹងទេ ត្រូវតែសុំទោស នៅពីមុខអ្នករងគ្រោះចំៗ ហើយសងគ្រប់អ្វីតាមគេចង់បាន!»

គន្ធាធ្វើហ៊ឺះ៖

«គេឈឺច្រើនឆ្នាំមិនទាំងចាំបានថា ខ្លួនគេជាអ្នកណាផង!»

ថាហើយអូសដៃដាណេនិងធីតាចាកចេញ។ ដោយគ្មានដំណោះស្រាយអ្វីល្អ ដាណេនិងធីតាក៏ចាកចេញ។

**ម៉ោងប្រាំពីរយប់**....

«អូនស្គាល់ទេ! អ្នកគ្រូស៊ីណាត!»

ស្ទើរបុកពោះម្ដងទៀតពេលប្ដីហុចព័ត៌មានមកឱ្យមើល។

«អ្នកណា? រឿងអីទៅ?»

តាមពិតនឹកឃើញនិងស្គាល់គ្រូនេះច្បាស់ ព្រោះជាមនុស្សដែលទើបនឹងខលមកសម្លុតទារប្រាក់ម្សិលមិញ។

«អានបន្តិចទៅ»

គន្ធាមិនចង់មើលទេ តែប្ដីធ្វើមុខស្មើ ហុចមកទៀត។

គន្ធាមានខ្លួន។

កាលពីមុនបានពឹងអ្នកគ្រូនេះឱ្យក្លែងសំបុត្រ។ ម្សិលមិញឱ្យខ្លួនលក់ហាងយកលុយឱ្យគន្ធាមិនធ្វើតាមប្រហែលជា.....បានហែកកេរ្ត៍ឬអ្វីហើយ។

កំពុងទទួលមកអានទាំងចិត្តត្រៀមថា នឹងប្រកែកតវ៉ាឱ្យប្ដីព្រមស្ដាប់ស្រាប់តែគាំង ព្រោះពេលមើល.....ហើយមិនចាប់អារម្មណ៍អ្វីក្រៅតែពីឈាម.....ពីរនាក់ប្ដីប្រពន្ធសម្លឹងមើលឈាមដែលដាំនៅលើតដ្ឋនិងសាកសពគ្រប់មុខ។

ដៃគន្ធាខ្ទប់មាត់។

មើលតាមទូរសព្ទក៏ឃើញអ្នកគ្រូស៊ីណាតដេកស្លាប់ស្ដូកស្ដឹង ដោយដួលផ្ងារក្រោយ ផុងក្បាលទៅនឹងដែក។

នៅលើដៃគាត់មានប៊ិកនិងក្រដាស។

សន្លឹកscrollមួយទៀត ដេវីដបង្ហាញគន្ធា....

«មើលចុះ!»

នៅលើក្រដាសមានសរសេរថា«ទោសបន្លំសំបុត្រសិស្សដើម្បីយកប្រាក់! ថ្ងៃនេះ ត្រូវតែទទួលកម្ម!»

បេះដូងចង់គាំងផង គន្ធាឮស្នូររទេះមនុស្សពិការជិះរទេះ លាន់ចេញមកពីខាងក្រៅបន្ទប់។ នាងគាំងផងភ័យផង ងាកមកសន្សឹមៗរកប្ដីនឹងអាលថយទៅក្បែរ ប៉ុន្តែ.....បែរជាមិនមែនដេវីដ។

រូបរាងដូនចាស់ជិះរទេះ បានបង្ហាញខ្លួនញញឹមក្បែរនាង។

ស្រីមុំធាក់ថយលើពូកស្រែកមិនចេញ។

ដូនចាស់និយាយទាំងញញឹម៖

«ដល់ពេលហើយ!»

នៅមាត់ទ្វារមានគេបើក។

គន្ធាអរណាស់ស្មានថាមានអ្នកឡើងមកជួយទាន់ តែកង់មនុស្សពិការដែលបានមកដល់ គឺផ្ទុកនូវរូបរាងអតីតមិត្តកម្សត់គឺស្រីមុំ។ គន្ធាហាមាត់ធំៗ អស់ខ្យល់ស្រែក។

ស្រីមុំដែលស្គមស្គាំងបិទភ្នែក ប៉ុន្តែរុញរទេះមកលើបន្ទប់ដេកនេះបានដោយរបៀបណា?

ខ្មោចពិតហើយ!

នេះជាអ្វីដែលខួរក្បាលគន្ធាប្រាប់គន្ធា តែនាងនៅតែបិទភ្នែកប្រកែក៖

«មិនពិត! យើងគិតបំភាន់ខ្លួនយើង! មិនពិត! លោកនេះគ្មានរឿងអស់នេះទេ!»

នៅតែឮសំឡេងរទេះលូនចូលមកកាន់តែច្បាស់ គន្ធាមានអារម្មណ៍ចោមព័ទ្ធដោយខ្យល់ត្រជាក់។

«គន្ធា! សងជីវិតយើងវិញ!»

«ស្រីមុំ! យើងមិនដឹងអីទេ! យើងមិនដែលស្រឡាញ់ដេវីដទេ!»

បើកភ្នែកមកឃើញស្រីមុំនៅអង្គុយសំកុកកៀកនឹងមុខ។ គន្ធាស្រែកនិងលើកដៃទះស្រីមុំមួយទំហឹង ដៃស្តាំត្រូវស្រីមុំចាប់ជាប់។

គន្ធាខំប្រឹងស្រែកម្តបៗព្រោះភ្នែករបស់ស្រីមុំគ្មានប្រស្រីទេ។ ទោះរើយ៉ាងណាក៏ដកដៃមិនរួចស្រែកមិនឮ។ ស្រីមុំសើចស្ងាញ លូកដៃម្ខាងទៀតមកដកចិញ្ចៀនរៀបការចេញពីក្នុងម្រាមដៃនាងរបស់គន្ធា។

ហើយ.....និយាយឡើងដោយសំឡេងអន្លាយៗអួលៗ៖

«ឯងរៀបការជាមួយសង្សារអញ!»

បីថ្ងៃក្រោយមក ទាំងឪពុកម្តាយរបស់គន្ធានិងដេវីដ ដើររកកូនស្រីនិងមិត្តទាំងពីរគ្រប់ទីកន្លែង មិនឃើញដំណឹងទាល់តែសោះ។

ស្រាប់តែមកឮគេនិយាយថា នៅភ្នំពេញក្បែរសាកលវិទ្យាល័យដែលពួកគេធ្លាប់រៀន ឃើញមានមនុស្សស្រីពាក់អាវកូនក្រមុំប្រឡាក់ឈាមហើយអង្គុយក្បែរសាកសពមិត្តភក្តិពីរនាក់ ដៃមានកាន់កាំបិតមួយ។

ម្នាក់នោះ គឺគន្ធាដែលបានចាក់សម្លាប់ធីតានិងដាណេដោយខ្លួនឯង។

ចំណែកខ្លួននាងពាក់អាវកូនក្រមុំដែលប្រឡាក់ពេញទៅដោយឈាម។

**ប្រាំមួយខែក្រោយមក**

ដេវីដនៅអង្គុយក្បែររទេះរបស់ស្រីមុំហើយនិយាយប្រាប់ឡើងថា៖

«គន្ធាបានសម្លាប់ដាណេនិងធីតាហើយបានត្រូវយកទៅឃុំនៅពេទ្យឆ្កួត! អាការៈនាងកាន់តែឆ្កួតឡើង! មិនដឹងជាហេតុអីបានជាគន្ធាត្រូវសម្លាប់ធីតានិងដាណេ! ប៉ូលិសថា គន្ធាបានសម្លាប់ទាំងអ្នកគ្រូស៊ីណាតរបស់អូនផងនឹកឃើញគាត់ទេ?»

ស្រីមុំញញឹម។

ជាលើកដំបូងក្រោយរយៈពេលរបួស៥ឆ្នាំ ដែលនាងបានញញឹមរួច។

ជាបន្តបន្ទាប់នាងចាប់ផ្តើមហៅឈ្មោះគន្ធារហូតដល់ដាច់ដង្ហើម។

ចាប់ពីពេលនោះទៅគ្មានមិត្តភក្តិស្រីទាំងបួនដែលពួកគេធ្លាប់ឃើញនោះទៀតទេ។ ដេវីដបានធ្វើបុណ្យឱ្យស្រីមុំនិងផ្តល់ប្រាក់កាសខ្លះឱ្យម្តាយនាងធ្វើផ្ទះឡើងវិញ ក៏ដូចជាទុកទ្រទ្រង់ជីវភាព។ ចំណែក គន្ធាបានរស់នៅជាមួយនឹងការសងកម្មក្នុងទីវិកល។

**ដកពាក្យទំនាយ**

ថ្ងៃនេះ ដេវីដបានត្រូវឪពុកម្តាយក្មេកបបួលមកប្រាប់រឿងសំខាន់ថា ពួកគេបានស្វែងរកនូវរឿងរ៉ាវទាំងអស់ ទាក់ទងទៅមនុស្សដែលគន្ធាបានជួបជាចុងក្រោយគេមុនពេលសម្លាប់មិត្តរបស់ខ្លួន គឺដូនស្លៀកពាក់សនៅវត្ត។

ពួកគាត់ចង់ឱ្យកូនប្រសាជួយនាំទៅរកយាយនោះ សួររកខុសត្រូវ។

«ខ្ញុំមកនេះមកសុំអង្វរយាយឱ្យជួយប្រាប់ការពិតផង! ថាថ្ងៃនោះ មុនទៅភ្នំពេញនិងសម្លាប់មិត្តភក្តិគេមានគេឃើញកូនខ្ញុំនាំធីតានិងដាណោមករកយាយ តើពួកគេមានរឿងទំនាស់អ្វីជាមួយគ្នា! ខ្ញុំយល់ថាកូនខ្ញុំគ្មានទោសទេ! ប្រាកដជាមានអ្នកទីបួន ដែលធ្វើរឿងនេះ ហើយទម្លាក់កំហុសលើកូនស្រីខ្ញុំ!»

លោកយាយដកដង្ហើមធំ៖

«នៅពេលដែលមនុស្សយើងដឹងកំហុស ទើបគ្រប់យ៉ាងអាចក្លាយទៅជាទទេ! ហើយទើបនឹងអាចដោះលែងខ្លួនឯងពីកម្មផលបាន!»

«អ្នកណាដែលធ្លាប់ធ្វើកម្មអាក្រក់ទៅ? ចង់សំដៅកូនខ្ញុំមែនទេ? វាចិត្តល្អណាស់យាយ! មានមិត្តពិការវាឱ្យលុយម្តាយគេថែជំងឺកូនរាល់ខែ!» ម្តាយគន្ធានៅតែការពារកូនទាំងជូតទឹកភ្នែក។ លោកយាយមិនឆ្លើយឆ្លងនៅតែសូត្រទ្រឹស្តីទន្ទេញៗថា៖

«សូម្បីតែសេចក្តីស្លាប់ក៏មិនអាចលុបលាងអំពើល្អបានដែរ ចុះទម្រាំអំពើអាក្រក់»

ឪពុកនាងដឹងថាពិបាកនិយាយគ្នាក៏លូកមាត់ឡើងម្តង៖

«អុំអើយអុំ កូនខ្ញុំមានតែមួយ ឥឡូវនាងនៅក្នុងមន្ទីរពេទ្យឆ្កួត! រងទុក្ខវេទនាជាខ្លាំង! មានគេធ្វើបាបគ្រប់កន្លែង!»

យាយគ្រវីក្បាលងាកសម្លឹងទឹកភ្នែកម្តាយហើយដាច់ចិត្តប្រាប់៖

«អ្នកជាមេអើយ! វាជាពាក្យទំនាយ! កូនម្នាលនឹងត្រូវទទួលទុក្ខកម្មទាំងស្រុងរហូតដល់ទាំងអស់អ្វីពីខ្លួន»

ប្រពន្ធយំគគ្រុក។

ប្ដីប្រពន្ធទាំងទ្វេជាអ្នករកស៊ី ធ្លាប់ហើរដើរគ្រប់ទិសទីនៅបាត់ដំបង ក៏ធ្លាប់ឮគេនិទានតំណាលខ្លះៗពាក់ព័ន្ធរឿងពាក្យ«ទំនាយ»នេះ ថាមិនងាយសាបរលាបទេ។ តើកូនខ្លួនទៅត្រូវទំនាយពីណាមក? ពួកគាត់មិនដឹងឡើយ បានត្រឹមងាកមកសម្លឹងកូនប្រសាឱ្យជួយគិតគ្នា។

ដេវីដចាប់ផ្ដើមលែងលាក់បាំង។

គេងក់ក្បាល៖

«មុនទៅភ្នំពេញ យប់នោះពេលគេចេញពីវត្តវិលមកផ្ទះវិញ ប្រពន្ធខ្ញុំដូចជាតុកស៊ុកណាស់! គេមិនមាត់មិនក មិនងូតទឹកផ្លាស់អ្វីទេអង្គុយហូបស្រាហូតដល់ស្រវឹងស្រាអួរទីន្ទ។ ពេលខ្ញុំចូលទៅឃាត់ គន្ធាបាននិយាយសារភាពគ្រប់យ៉ាងប្រាប់ប្ដី។ ខ្ញុំខឹងណាស់ ខ្ញុំដឹងរឿងទាំងអស់ដែលកើតឡើងចំពោះស្រីមុំ ក៏ដើរចោលគន្ធាផ្ទះមួយយប់ ព្រោះទទួលយកមិនទាន់បានការពិតទាំងនោះ គេថា.....គេបានច្រានមិត្តរបួសនិងច្រឡំជ្រុលដៃប្រតាយរុញយាយគេធ្លាក់ទឹក!»

ម្ដាយសម្លឹងមើលកូនប្រសាយ៉ាងតក់ស្លុត។ មិននឹកស្មានថា គាត់មកឮរឿងទាំងនេះក្នុងពេលនេះសោះ។ ងាកមកយាយសក់សដូចមិនមានមានភ្ញាក់ផ្អើលអ្វីទេ។ គាត់នៅស្ងៀមមុខស្មើដដែលគិតពីសូត្រធម៌។

ដេវីដនិយាយបន្ត៖

«មិនដែលនឹកស្មានទេថាខ្ញុំចេញចោលគេបន្តិច ពេលនោះគេក៏ទៅធ្វើរឿងបែបនេះជាមួយមិត្តគេ! ទៅសម្លាប់គ្នានៅភ្នំពេញ»

**អ្វីគ្រប់យ៉ាងដែលមានការចាប់ផ្ដើមរមែងមានទីបញ្ចប់**

ចាប់ពីពេលនោះមក ឪពុកម្ដាយរបស់គន្ធាតែងតែព្យាយាមតាមរកបណ្ដាអ្នកចេះផ្លូវងងឹតពូកែៗឱ្យជួយរំដោះកម្មពៀរកូនស្រី។

គាត់បានមកដល់ស្រុកថ្មគោល និងជួបអ៊ំម្នាក់ជាអ្នកស្រុកឯកភ្នំ។

«ខ្ញុំមានកូនស្រីម្នាក់នាងឈ្មោះគន្ធា កើតថ្ងៃ១៥ ខែមិគសិរ ឆ្នាំ១៩៩៤! ខ្ញុំដឹងថា នាងបានធ្វើខុសធ្ងន់រងពាក្យទំនាយមនុស្សជិតស្លាប់! ខ្ញុំជាឪពុកម្ដាយ អាចសងកម្មនេះ ជំនួសនាងបានទេលោកតា??!»

«គ្មានអ្នកណាអាចសងកម្មជំនួសអ្នកណាបាននោះទេ នេះគឺជាក្រឹត្យក្រមនៃវដ្ដសង្សា!» អ៊ំប្រុសបានប្រាប់វិញដោយគ្រវីក្បាលព្រោះពេលស្ដាប់ឈ្មោះនិងថ្ងៃកើត គាត់រាប់ដៃគន់គូរដឹងទៅហើយអំពីហេតុភេទសព្វសារពើ។

«ដូច្នេះមានន័យថា គ្មានមធ្យោបាយទេឬ?» ឪពុកសួរទាំងព្រិចភ្នែក នឹកដល់កូនស្រីទោលតែមួយដែលត្រូវរងជំងឺឆ្កួតវង្វេងយ៉ាងមានបាប។

«សូមអ្នកទាំងពីរ ទុកឱ្យនាងបានទទួលនូវអ្វីដែលជាលទ្ធផលរបស់នាង!»

ម្ដាយជូតទឹកភ្នែកពោលប្រកែកៈ

«ប៉ុន្តែ....ខ្ញុំជាឪពុកម្ដាយ....ឃើញកូនបែបនេះ ខ្ញុំសុខចិត្តស្លាប់ មិនព្រមមើលកូនវេទនាបែបនេះរហូតដល់ចាស់ទេ! អ៊ំមានបញ្ញាមកប្រោសសត្វ! ប្រាកដជាមានវិធី!»

ដោយគន់គូរចុះឡើងនិយាយជាមួយខ្យល់និងដើមឈើ បុរសចម្លែកបានឱ្យចម្លើយមកជនចំណាស់ទាំងពីរថាៈ

«ឱអ្នកជាឪពុកម្ដាយ! បុណ្យដែលកូនស្រីរបស់អ្នកអាចសងទៅលើផែនដីវិញ គឺតោងធ្វើដោយក្ដីអត់ធ្មត់»

គាត់ឱនមកខ្សឹបប្រាប់វិធីហើយ តមកញាតិតែងឃើញឪពុកម្ដាយគន្ធា លក់កេរអាករទាំងអស់ ដើរស្វះស្វែងរកជនពិការសឹងគ្រប់ទីកន្លែង ហើយធ្វើបុណ្យជាមួយពួកគេ រហូតដល់គម្រប់៥០០០ពាន់នាក់។

រយៈពេលដប់ប្រាំបីខែក្រោយមក ក៏ទទួលបានដំណឹងពីក្នុងមន្ទីរពេទ្យមកវិញថា គន្ធាបានបាត់បង់ជីវិតនៅក្នុងអាងទឹកតូចមួយ ដែលមិនសមថាអាចលង់ស្លាប់នោះទេ។

សពនាងមិនត្រឹមតែអណ្ដែតឡើងមក ដោយដៃទាំងពីរបោះទៅលើ ថែមទាំងមានប្រឡាក់ឈាមជោកជាំពេញដៃ។

ឪពុកម្ដាយនាងឮហើយ ក៏បិទភ្នែកស្រក់ទឹកភ្នែកស្ងាត់ស្ងៀម។

ទោះបីយ៉ាងណាគោលបំណងរបស់គាត់បានសម្រេចហើយ។ ទោះណាជាកូនស្រីទោលរបស់គាត់គ្មានថ្ងៃអាចវិលត្រឡប់មកជាគន្ធាដូចពេលពីមុនវិញ ដោយសារកម្មរបស់នាងដែលហ៊ានសម្លាប់មនុស្សបង្ហូរឈាមនិងមិនចេះដឹងខ្លួន មិនដែលទទួលកំហុស អ្វីដែលឪពុកម្ដាយអាចធ្វើសម្រាប់គន្ធាបានគឺឱ្យនាងឆាប់ស្លាប់ អស់កម្មអាចទៅចាប់ជាតិថ្មី។

តើអ្នកយល់យ៉ាងណាចំពោះប្រលោមលោកមួយនេះ?

ប្រសិនយល់ថាមានគតិល្អជួយផ្សព្វផ្សាយជូនអ្នកនិពន្ធផង។